# សលាកប័ត្រព័ត៌មាន ៖ កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សពីសំណាក់ធុរកិច្ច

**ទិដ្ឋភាពរួម ៖** ជាផ្នែកមួយនៃធុរកិច្ចនិងសិទ្ធិមនុស្សដែលពិភាក្សាលើកាតព្វកិច្ចរបស់ក្រុមហ៊ុនក្នុងការគោរពសិទ្ធិមនុស្សនៅគ្រប់ទីកន្លែងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ និងពិភាក្សាលើការទំនួលខុសត្រូវរបស់រដ្ឋពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រុមហ៊ុនទាំងនោះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សូមបង្ហាញនូវទិដ្ឋភាពទូទៅស្តីពីទំនួលខុសត្រូវ និងកាតព្វកិច្ចពាក់ព័ន្ធនានារបស់រដ្ឋក្នុងការធានាថាក្រុមហ៊ុនចម្រុះជាតិសាសន៍ និងក្រុមហ៊ុនដទៃទៀតដែលប្រតិបត្តិការធុរកិច្ចនៅលើដែនដីរបស់ខ្លួននឹងមិនរំលោភបំពានសិទ្ធិមនុស្សនោះឡើយ ។ ជាពិសេស សលាកប័ត្រព័ត៌មាននេះរៀបរាប់ពីជំហានជាក់លាក់មួយចំនួនដែលមានក្នុងគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។

## សេចក្តីផ្តើម

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ការវិនិយោគពីសំណាក់ធុរកិច្ចជាតិ និងអន្តរជាតិ គឺជាកត្តាសំខាន់ក្នុងការជំរុញដល់ការអភិវឌ្ឍន៍ជាតិ ។ ប៉ុន្តែជាញឹកញាប់ ការរំលោភសិទ្ធិមនុស្សដូចជាការបំពានយកដីធ្លី ឬការរឹតត្បិតលើសេរីភាពបញ្ចេញមតិ តែងប៉ះពាល់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយជនរងគ្រោះភាគច្រើនគឺជាក្រុមដែលងាយរងផលប៉ះពាល់បំផុតនៅក្នុងសង្គមរួមមាន ស្ត្រី និងជនជាតិដើមភាគតិចជាដើម ។ នេះជាមូលហេតុដែលទស្សនៈទានស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា ។ ទស្សនៈទាននេះសំដៅដល់ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិទាំងឡាយណាដែលអាចអនុវត្តបានចំពោះសកម្មភាពរបស់ធុរកិច្ចដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានកើតចេញពីសកម្មភាពធុរកិច្ចដែលអាចប៉ះពាល់ទៅលើសិទ្ធិមនុស្ស។ គោលការណ៍គន្លឹះចំនួនបីរៀបរាប់បញ្ជាក់ពីទស្សនៈទាននេះគឺ កាតព្វកិច្ចរបស់រដ្ឋដើម្បីការពារប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្សពីប្រតិបត្តិការរបស់ធុរកិច្ច ទំនួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងការគោរពសិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋនិងក្រុមហ៊ុនក្នុងការផ្តល់នូវដំណោះស្រាយមួយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភសិទ្ធិមនុស្ស ។

សលាកប័ត្រព័ត៌នេះធ្វើឡើងក្នុងគោលបំណងបង្ហាញនូវទិដ្ឋភាពទូទៅនៃកាតព្វកិច្ចរបសរដ្ឋក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សពីប្រតិបត្តិការរបស់សហគ្រាស ។ សលាកប័ត្រព័ត៌មាននេះត្រូវបានរៀបចំឡើងដោយ ម.ស.មក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្សពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

## ច្បាប់ពាក់ព័ន្ធ

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានដាក់បញ្ចូលសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទៅក្នុងច្បាប់ជាតិដោយផ្ទាល់។ លើសពីនេះទៅទៀត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ បានពង្រឹងគោលជំហរនៃការគោរពសិទ្ធិមនុស្សដោយប្រកាសថា គ្រប់សន្ធិសញ្ញាអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័នអាចយកទៅអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ជាតិ ។[1]

ស្ទើរតែគ្រប់សិទ្ធិមនុស្សទាំងអស់អាចរងផលប៉ះពាល់អវិជ្ជមានពីសំណាក់ប្រតិបត្តិការរបស់ធុរកិច្ច ។ នៅក្នុងបរិបទនៃប្រទេសកម្ពុជា សិទ្ធិមួយចំនួនត្រូវបានគំរាមកំហែងដោយសកម្មភាពរបស់ក្រុមហ៊ុនដូចជា ៖

- សិទ្ធិជាម្ចាស់កម្មសិទ្ធិ[2]
- សិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ និងការការពារប្រឆាំងទៅនឹងការបណ្តេញចេញដោយបង្ខំ[3]
- សិទ្ធិមិនទទួលរងការជ្រៀតជ្រែកក្នុងជីវិតឯកជន គ្រួសារ និងលំនៅដ្ឋាន[4]
- សិទ្ធិទទួលបានសុខភាព[5]
- សិទ្ធិមានការងារធ្វើ[6]
- សេរីភាពក្នុងការធ្វើដំណើរ និងជ្រើសរើសនិវេសនដ្ឋានរបស់ខ្លួនដោយសេរី[7]
- សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងការប្រមូលផ្តុំ និងសេរីភាពខាងសមាគម[8]
- សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[9]
- សិទ្ធិទទួលបានដំណោះស្រាយចំពោះការរំលោភបំពានសិទ្ធិមនុស្ស[10]

---

[1] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៧ ។

[2] មាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[3] មាត្រា១១ (កថាខណ្ឌទី១) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

[4] មាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[5] មាត្រា១២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

[6] មាត្រា៦ (កថាខណ្ឌទី១) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

[7] មាត្រា១២ (កថាខណ្ឌទី១) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[8] មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[9] មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[10] មាត្រា២ (កថាខណ្ឌទី៣) និងមាត្រា២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

នេះជាគោលការណ៍មូលដ្ឋានដែលបុគ្គលគ្រប់រូបនៅក្នុងយុត្តាធិការរបស់ប្រទេសនីមួយៗត្រូវតែគោរពច្បាប់របស់ប្រទេសនោះ រួមទាំងសិទ្ធិមនុស្សផងដែរ ។ ការគោរពច្បាប់ និងសិទ្ធិមនុស្សនេះក៏រួមបញ្ចូលទាំងនីតិបុគ្គលផងដែរដូចជាក្រុមហ៊ុនវិនិយោគជាដើម ។

តាមរយៈការផ្តល់សច្ចាប័នដល់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចាត់វិធានការដាក់លាក់ដើម្បីបង្ការ និងការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សទាំងអស់ ។ មានន័យថា កម្ពុជាគួរតែអនុម័តច្បាប់ និងវិធានការចាំបាច់ណាមួយដើម្បីធានាថាសិទ្ធិមនុស្សទាំងអស់ត្រូវបានការពារប្រកបដោយប្រសិទ្ធភាព ។[11]

## តើរដ្ឋគួរអនុវត្តចំពោះបុគ្គលណាខ្លះ?

កាតព្វកិច្ចរបស់រដ្ឋដើម្បីធានាដល់ការគោរពសិទ្ធិមនុស្ស គ្របដណ្តប់រាល់សកម្មភាពរបស់គ្រប់ធុរកិច្ចទាំងអស់ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា មិនថាជាធុរកិច្ចដែលគ្រប់គ្រងដោយជនជាតិខ្មែរ ឬ បរទេសឡើយ ។ ក្រុមហ៊ុនដែលគ្រប់គ្រងដោយរដ្ឋមានកាតព្វកិច្ចកាន់តែតឹងរឹងថែមទៀតក្នុងការគោរពសិទ្ធិមនុស្ស ។ ដោយសារក្រុមហ៊ុនទាំងនោះត្រូវបានរដ្ឋគ្រប់គ្រងដោយពេញលេញឬមួយផ្នែក ដូចនេះកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋត្រូវអនុវត្តន៍ដោយផ្ទាល់ចំពោះប្រតិបត្តិការរបស់ពួកគេ ។ លើសពីនេះទៀត រដ្ឋត្រូវធានាថាក្រុមហ៊ុន ឬអ្នកវិនិយោគសញ្ជាតិខ្មែរដែលកំពុងប្រតិបត្តិការធុរកិច្ចនៅក្រៅប្រទេសមិនរំលោភបំពានសិទ្ធិមនុស្សឡើយ ។

## តើរដ្ឋអាចធ្វើអ្វីខ្លះ?

ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានអនុម័តក្របខ័ណ្ឌបទដ្ឋានមួយដើម្បីជួយណែនាំដល់រដ្ឋ និងក្រុមហ៊ុនឱ្យគោរពសិទ្ធិមនុស្សគឺគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។[12] ដោយសាររដ្ឋមានភាពពាក់ព័ន្ធ គោលគំនិតជាមូលដ្ឋាននោះគឺរដ្ឋត្រូវបង្កលក្ខណៈអំណោយផលដែលធុរកិច្ចអាចប្រតិបត្តិគោរពសិទ្ធិមនុស្ស ។ រដ្ឋអាចធ្វើឡើងតាមមធ្យោបាយពីរយ៉ាង គឺតាមរយៈការបង្ការពីការរំលោភសិទ្ធិមនុស្ស និងការពារពលរដ្ឋការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស និងតាមរយៈការផ្តល់នូវដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពក្នុងករណីមានការរំលោភបំពានសិទ្ធិមនុស្ស ។

ច្បាប់សិទ្ធិមនុស្ស ផ្តល់សេរីភាពដល់រដ្ឋក្នុងការសម្រេចលើចំណាត់ការណាមួយដើម្បីបញ្ចៀសការរំលោភបំពានសិទ្ធិមនុស្សពីសំណាក់ធុរកិច្ចអោយតែចំណាត់ការនោះមានប្រសិទ្ធិភាព ។ ប៉ុន្តែគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិផ្តល់ជាឧទាហរណ៍មួយចំនួននៃការចាត់ចំណាត់ការដូចជា ៖

---

[11] មាត្រា២ (កថាខណ្ឌទី២) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[12] គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖ ការអនុវត្តក្របខណ្ឌអង្គការសហប្រជាជាតិស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ" ថ្ងៃទី១៦ ខែមិថុនាឆ្នាំ២០១១ https://bit.ly/2tdULBz.

- ❖ អនុម័តច្បាប់ដែលគ្រប់គ្រងបញ្ហាប្រតិបត្តិការរបស់ធុរកិច្ច និងផលប៉ះពាល់របស់ពួកគេទៅលើសិទ្ធិមនុស្ស ។
- ❖ អនុម័តផែនការសកម្មភាពជាតិស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្ស ដែលមានជំហានជាក់ស្ដែងក្នុងការអនុវត្តគោលការណ៍ណែនាំស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។
- ❖ ពិគ្រោះយោបល់ជាមួយអ្នកពាក់ពន្ធ័ រួមមានក្រុមហ៊ុន ប៉ុន្តែអ្នកពាក់ព័ន្ធទាំងនោះអាចជាសមាជិក នៃសហគមន៍ដែលរងផលប៉ះពាល់ និងអ្នកតំណាងសង្គមស៊ីវិលផងដែរ ។
- ❖ ផ្សព្វផ្សាយព័ត៌មានអំពីកាតព្វកិច្ចរបស់ធុរកិច្ច ក្នុងការគោរពសិទ្ធិមនុស្ស ។
- ❖ ផ្ដល់ការណែនាំដល់បណ្ដាក្រុមហ៊ុនអំពីការគោរពសិទ្ធិមនុស្ស ។ ឧទាហរណ៍ ការចេញផ្សាយគោលការណ៍ណែនាំ ។
- ❖ ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីធានាថាធុរកិច្ចមានបុគ្គលភាពគតិយុត្តិ និងអាចទទួលខុសត្រូវខាងទណ្ឌកម្មព្រហ្មទណ្ឌ ក្នុងករណីមានការរំលោភសិទ្ធិមនុស្ស
- ❖ ទាមទារឱ្យមានការវាយតម្លៃអំពីផលប៉ះពាល់សិទ្ធិមនុស្សដែលត្រូវធ្វើមុននឹងអនុម័តគម្រោងអភិវឌ្ឍន៍នានា ព្រមទាំងត្រូវពិនិត្យតាមដានការគោរពសិទ្ធិមនុស្សឱ្យបានជិតដល់បំផុត ។
- ❖ ដើម្បីធានាថាក្រុមហ៊ុនណាដែលផ្ដល់សេវាកម្មលទ្ធកម្មដល់រដ្ឋមិនពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិមនុស្សទេតាមរយៈការវាយតម្លៃលើការត្រួតពិនិត្យដ៏ត្រឹមត្រូវ និង ឬ/ពិនិត្យប្រវត្តិរបស់ក្រុមហ៊ុននោះ ។

បន្ថែមពីនេះទៀត រដ្ឋត្រូវតែធានាថារាល់ការរំលោភសិទ្ធិមនុស្សណាមួយត្រូវបានដោះស្រាយឲ្យបានត្រឹមត្រូវ ។ លើសពីនេះទៀត រដ្ឋត្រូវធានាថាបុគ្គលដែលរងការរំលោភសិទ្ធិ ឬសេរីភាព ត្រូវទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពតាមរយៈអាជ្ញាធរមានសមត្ថកិច្ចដូចជា នីតិបញ្ញត្តិ អាជ្ញាធររដ្ឋបាល ឬតុលាការ ឬតាមរយៈអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតដែលផ្ដល់ដោយប្រព័ន្ធច្បាប់រដ្ឋ[13] ជាពិសេសការទទួលខុសត្រូវរបស់រដ្ឋដើម្បីធានាថារាល់ដំណោះស្រាយដែលរដ្ឋផ្ដល់ជូនត្រូវបានអនុវត្តឲ្យបានពិតប្រាកដ ។[14]

**ករណីសិក្សា ៖ បុរីកីឡាភ្នំពេញ**

ក្នុងឆ្នាំ២០០៣ ក្រុមហ៊ុនផានអ៊ីមិចទទួលបានសម្បទានដីសង្គមកិច្ចនៅសហគមន៍បុរីកីឡាក្នុងកណ្ដាលទីក្រុងភ្នំពេញ ។ ជាថ្នូរដើម្បីអាចអភិវឌ្ឍតំបន់នោះសម្រាប់គោលបំណងពាណិជ្ជកម្មបាន ក្រុមហ៊ុនត្រូវទទួលខុសត្រូវសាងសង់អគារលំនៅដ្ឋានចំនួន ១០ អគារនៅលើទីតាំងនោះក្នុងគោលបំណងជូនទៅប្រជាពលរដ្ឋចំនួន

---

[13] មាត្រា២ (កថាខណ្ឌទី៣) កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[14] មាត្រា២ (កថាខណ្ឌទី៣) កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

១៧៧៦ គ្រួសារ ដែលរងការប៉ះពាល់ដោយសារគម្រោងក្រុមហ៊ុននេះ ។[15] ក្នុងឆ្នាំ២០១០ ក្រុមហ៊ុនផានអ៊ីមិច បានខកខានគោរពតាមការសន្យារបស់ខ្លួន ដោយសាងសង់អគារបានត្រឹមតែចំនួន ៨ ដែលទុកឲ្យប្រជាពលរដ្ឋចំនួន ៣៨០ គ្រួសារពុំទទួលបានសំណងត្រឹមត្រូវពីគម្រោងរបស់ក្រុមហ៊ុន ដោយសំអាងហេតុថា ក្រុមហ៊ុនក្ស័យធន ។ នៅខែមករា ឆ្នាំ២០១២ ផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារទាំងនោះត្រូវបានបំផ្លិចបំផ្លាញក្រោមការត្រួតពិនិត្យពីសំណាក់កំលាំងប៉ូលីស ដោយពុំមានការជូនដំណឹងជាមុននៅខែមករា ឆ្នាំ២០១២ ។

ក្នុងពេលនោះ ប្រជាពលរដ្ឋពាក់កណ្តាលបានប្តូរទៅកាន់ទីតាំងថ្មីនៅខាងក្រៅរាជធានីភ្នំពេញដែលផ្តល់ជូនដោយសាលារាជធានីភ្នំពេញ ប៉ុន្តែដោយសារនៅទីតាំងថ្មីនោះ ខ្វះទឹកស្អាត សេវាសំខាន់ៗដូចជាបង្គន់អនាម័យ អគ្គិសនី ព្រមទាំងការងារនិងឱកាសទទួលបានការសិក្សា ប្រជាពលរដ្ឋមួយចំនួនបានវិលត្រឡប់មកបុរីកីឡាវិញ ខណៈដែលប្រជាពលរដ្ឋប្រមាណពាក់កណ្តាលទៀត បានស្នាក់នៅជាមួយបងប្អូននៅកន្លែងផ្សេងៗគ្នានៅរាជធានីភ្នំពេញ ហើយបន្ទាប់មកក៏ត្រឡប់មកស្នាក់នៅបុរីកីឡាវិញដដែល ។

ជាលទ្ធផលនៅក្នុងឆ្នាំ២០១៤ សាលារាជធានីភ្នំពេញបានរៀបចំវេទិកាសាធារណៈមួយហើយបានរកឃើញថា ប្រជាពលរដ្ឋចំនួន ១៥៤ គ្រួសារបានរស់នៅក្នុងខ្ទមស័ង្កសី លើគំនរសំរាម និងនៅក្រោមអគារទាំង ៨ នោះ ដើម្បីទាមទារសំណងសមរម្យ ។ នៅក្នុងឆ្នាំ២០១៤ សាលារាជធានីភ្នំពេញបានដើរតួនាទីដោះស្រាយជំលោះដោយបានរៀបចំជាវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ជាច្រើនដង ដើម្បីស្រង់បញ្ជីឈ្មោះគ្រួសារដែលទាមទារនីមួយៗ និងវាយតម្លៃលើឯកសារពាក់ព័ន្ធផ្សេងៗ ថាតើគ្រួសារណាខ្លះនឹងទទួលបានសំណង ។ អង្គការសង្គមស៊ីវិល ក៏ត្រូវបានអនុញ្ញាតឲ្យចូលរួមឃ្លាំមើលលើវេទិកានោះផងដែរ ។ បន្ទាប់ពីការពិភាក្សាជាច្រើនលើករវាងគ្រួសារពលរដ្ឋដែលរងផលប៉ះពាល់និងសាលារាជធានីភ្នំពេញ ប្រជាពលរដ្ឋភាគច្រើនបានយល់ព្រមទទួលយកសំណង ទោះបីជាពួកគាត់មានអារម្មណ៍ថាពុំទទួលបានសំណងពេញលេញតាមការបាត់បង់របស់ខ្លួនក្តី ។ គ្រួសារចំនួន ១១ គ្រួសារក្នុងចំណោម១៥៤ នៅតែបន្តរស់នៅក្នុងអគារមួយជិតអតីតលំនៅដ្ឋានពីមុនរបស់ខ្លួនដោយរង់ចាំឲ្យមានដំណោះស្រាយសមរម្យ ។[16]

យោងតាមព័ត៌មានដែល ម.ស.ម.ក ទទួលបាន បច្ចុប្បន្ននេះ ប្រជាពលរដ្ឋចំនួន ៤ គ្រួសារ ក្នុងចំណោម ១១ គ្រួសារដែលនៅសេសសល់យល់ព្រមទទួលសំណងពីសាលារាជធានីភ្នំពេញហើយ ។ ប្រជាពលរដ្ឋចំនួន ៧គ្រួសារផ្សេងទៀតមិនព្រមទទួលយកសំណងនេះទេសារតែទីតាំងផ្តល់ឲ្យនោះស្ថិតនៅតំបន់ដាច់ស្រយាល ដែលខ្វះសាលារៀន ទីផ្សារ និងឱកាសការងារ ។ ក្រៅពីនេះ នៅមានគ្រួសារចំនួន ១០ គ្រួសារផ្សេងទៀតដែល

---

15 <u>សុបិន្តអាក្រក់របស់សហគមន៍បុរីកីឡា</u> កាសែត ដឹ ឌីភ្លូម៉ា ចេញថ្ងៃទី១៥ ខែមករា ឆ្នាំ២០១២

16 សេចក្តីថ្លែងការណ៍រួម "អង្គការសង្គមស៊ីវិលសូមអំពាវនាវដល់សាលារាជធានីភ្នំពេញទម្លាក់ចោលឱសានវាទចំពោះប្រជាពលរដ្ឋជាច្រើនគ្រួសារនៅបុរីកីឡានិងសូមផ្តល់សំណងសមរម្យជូនពួកគាត់ដោយកុំពន្យារពេល" ចេញថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ អាចរកបានតាមរយៈ https://bit.ly/2JQ251s ។ នៅពេលថ្ងៃផុតកំណត់ ប្រជាពលរដ្ឋបុរដ្ឋកីឡាបដិសេធការផ្តល់ជូនចុងក្រោយ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ https://bit.ly/2tbfaYJ ។ សេចក្តីថ្លែងការណ៍រួម "ក្រុមអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលថ្កោលទោសចំពោះការបណ្តេញពលរដ្ឋសហគមន៍បុរីកីឡាដោយហិង្សា" ចេញថ្ងៃទី៣ ខែមករា ឆ្នាំ២០១២ https://bit.ly/2JPTjk2.

មិនបានចូលរួមក្នុងវេទិកាសាធារណៈរបស់សាលារាជធានីភ្នំពេញកាលពីឆ្នាំ២០១៤ នៅតែបន្តរស់នៅ និងទាមទារ និងរង់ចាំសំណងសមរម្យផងដែរ ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ជាការសំខាន់ណាស់ដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវដើរតួយ៉ាងសកម្មក្នុងការបង្ការការរំលោភបំពានសិទ្ធិមនុស្សដែលប្រព្រឹត្តដោយធុរកិច្ច ឬដោយសារមកពីប្រតិបត្តិការរបស់ធុរកិច្ចទាំងនោះ ។ រដ្ឋក៏ត្រូវធានាផងដែរថា នៅពេលមានការរំលោភបំពានសិទ្ធិមនុស្សបែបនេះកើតមានឡើង ជនរងគ្រោះអាចទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព យុត្តិធម៌ និងឆាប់រហ័ស ។

### សំណូមពរដល់រាជរដ្ឋាភិបាល ៖

- អនុម័តផែនការសកម្មភាពជាតិ ស្តីពីការអនុវត្តគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដោយមានការពិគ្រោះយោបល់ជាមួយធុរកិច្ច និងតំណាងអង្គការសង្គមស៊ីវិល។
- ធ្វើឱ្យប្រសើរឡើងនូវការទទួលបានដំណោះស្រាយជូនជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្សដែលបង្កឡើងដោយធុរកិច្ច។
- តម្រូវអោយក្រុមហ៊ុននិងអ្នកវិនិយោគបរទេសទាំងអស់ដែលប្រតិបត្តិការនៅកម្ពុជា ធ្វើការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្សដោយឯករាជ្យ និងមិនលម្អៀង មុនពេលធុរកិច្ចទាំងនោះទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការនៅកម្ពុជា។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ចនិងសិទ្ធិមនុស្សនៃ ម.ស.ម.ក តាមរយៈទូរសព្ទលេខ +៨៥៥ (0) ១២ ៩៤១២០៦ ឬ អ៊ីម៉ែល**
**vann.sophath@cchrcambodia.org**

---ចប់---

cc BY NC SA